ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១៤៩១៣ អពដ

# សេចក្តីបំភ្លឺ

ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា មានប្រជាពលរដ្ឋដែលជាម្ចាស់យានយន្តដឹកទំនិញធុនធ្ងន់ នៅតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តត្បូងឃ្មុំ និងខេត្តព្រៃវែង ជាដើម បាននាំគ្នាស្នើសុំរក្សាការអនុវត្តការបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៦ ចំពោះរថយន្តដឹកទំនិញធុនធ្ងន់ ឱ្យនៅដូចឆ្នាំចាស់ដដែល (ឆ្នាំ២០១៥)។

អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការបំភ្លឺជូនសាធារណជន ជាពិសេស ម្ចាស់យានយន្តដឹកទំនិញធុនធ្ងន់ដែលបានតវ៉ាទាំងនោះ មេត្តាជ្រាបថា មូលហេតុនៃការកែសម្រួលប្រាក់ពន្ធ ចំពោះប្រភេទរថយន្តដឹកទំនិញធុនធ្ងន់ខាងលើ គឺដោយហេតុថា រថយន្តប្រភេទទាំងនេះអាច**បណ្តាលឱ្យប៉ះពាល់ខ្លាំងដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងបរិស្ថាន** ដែលរាជរដ្ឋាភិបាលបានចំណាយធនធានយ៉ាងច្រើនក្នុងការកសាង ជួសជុល ថែទាំ ម្យ៉ាងទៀត ប្រាក់ពន្ធនៃប្រភេទរថយន្តដឹកទំនិញទាំងនេះ **មិនធ្លាប់បានដំឡើងនៅឡើយទេ ចាប់តាំងពីបានដាក់ឱ្យអនុវត្តនៅឆ្នាំ១៩៩៨** រហូតមកដល់បច្ចុប្បន្ននេះ ដែលមានរយៈពេល ១៨ ឆ្នាំ មកហើយ។ លើសពីនេះទៀត **កម្រិតប្រាក់ពន្ធនៃប្រភេទរថយន្តដឹកទំនិញទាំងនេះនៅមានកម្រិតទាប បើធៀបទៅនឹងកម្រិតប្រាក់ពន្ធនៃប្រភេទរថយន្តទេសចរណ៍**ដែលត្រូវបានតម្លើងជាច្រើនដងរួចមកហើយ។ ការកែសម្រួលប្រាក់ពន្ធចំពោះរថយន្តដឹកទំនិញធុនធ្ងន់ខាងលើ ក៏ត្រូវបានធ្វើឡើងដើម្បីប៉ះប៉ូវការលុបចោលការប្រមូលពន្ធលើទោចក្រយានយន្ត និងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល ជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ សេះ ដែលការលុបចោលការប្រមូលពន្ធនេះ បានជួយសម្រាលបន្ទុកចំណាយរបស់ប្រជាពលរដ្ឋជាច្រើនលាននាក់ នៅទូទាំងប្រទេស ខណៈដែលការបង្កើនប្រាក់ពន្ធចំពោះរថយន្តដឹកទំនិញធុនធ្ងន់ខាងលើ គឺក្នុងគោលបំណងទ្រទ្រង់ដល់ចំណាយក្នុងការថែទាំផ្លូវដែលត្រូវទទួលរងការខូចខាតដោយសារការដឹកទំនិញធ្ងន់ៗទាំងនេះ ហើយនេះគ្រាន់តែជាការបង់បន្ថែម ចំពោះអ្នកដែលប្រកបអាជីវកម្មមួយចំនួនដែលមានប្រាក់ចំណូល។

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនសាធារណជន ជាពិសេស ម្ចាស់យានយន្តដឹកទំនិញធុនធ្ងន់ទាំងអស់មេត្តាជ្រាបផងដែរថា ការកំណត់ប្រាក់ពន្ធខាងលើនេះគឺជាការកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដូច្នេះ ក្នុងករណីមានការកែប្រែណាមួយ គឺទាមទារនូវការធ្វើវិសោធនកម្មច្បាប់នោះឡើងវិញ។ ក្នុងឋានៈជាស្ថាប័នអនុវត្តច្បាប់ អគ្គនាយកដ្ឋានពន្ធដារមិនអាចផ្តល់ការអនុគ្រោះចំពោះបុគ្គលណាម្នាក់បានទេ ម្យ៉ាងវិញទៀត ភាគច្រើននៃម្ចាស់រថយន្តដឹកទំនិញធុនធ្ងន់ បានមកប្រកាសបង់ពន្ធរួចរាល់ហើយដែរ។

ហេតុដូចនេះ អគ្គនាយកដ្ឋានពន្ធដារសូមម្ចាស់យានយន្តដឹកទំនិញធុនធ្ងន់ មេត្តាយោគយល់ និងអធ្យាស្រ័យខ្ពស់ ព្រមទាំងរួសរាន់មកបង់ប្រាក់ពន្ធតាមការកំណត់ដោយច្បាប់ ប្រកបដោយស្មារតីទទួលខុសត្រូវ និងសហការខ្ពស់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងម្ចាស់យានយន្តដឹកទំនិញធុនធ្ងន់ទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០១៦
**អគ្គនាយកដ្ឋានពន្ធដារ**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh